# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Dec-2011, 15:14
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ការបង្ហាញជូនរបស់សហព្រះរាជអាជ្ញា អំពីការធ្វើសម្ភាសន៍មួយជាមួយ ខៀវ សំផន និងសៀវភៅដែលមានចំណងជើងថា "នៅពីក្រោយវាលពិឃាតៈ មេដឹកនាំខ្មែរក្រហមម្នាក់ និងជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនរបស់គាត់" ដោយលោក GINA CHON និងលោក ថេត សម្បត្តិ

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | |
| | ចៅក្រម យូ ឧត្តរា | មេធាវីការពារក្តីជនជាប់ចោទ: |
| | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី: | លោក សុន អរុណ |
| | | លោក Michiel PESTMAN |

| | |
|---|---|
| ពេជ អង្គ | លោក Victor Koppe |
| Elisabeth SIMONNEAU FORT | លោក អាង ឧត្តម |
| | លោក Michael G. KARNAVAS |
| | លោក គង់ សំអុន |
| | លោក Jacques VERGÈS |

# I. សំណើ

១. អនុលោមតាមវិធាន៩២ និង៨៧(៤) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង មេត្តាដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវឯកសារដែលមានជូនភ្ជាប់ដូចខាងក្រោមនេះ៖

១) ខ្សែវីដេអូនៃការធ្វើសម្ភាសន៍ជាមួយជនជាប់ចោទឈ្មោះ ខៀវ សំផន (**ឧបសម្ព័ន្ធទី១**)។

២) សៀវភៅដែលមានចំណងជើងថា៖ "នៅពីក្រោយវាលពិឃាត៖ មេដឹកនាំខ្មែរមួយរូប និងជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនរបស់គាត់" ដោយលោក Gina Chon និងលោក ថេត សម្បត្តិ(**ឧបសម្ព័ន្ធទី២**)។

២. ការធ្វើសម្ភាសន៍ជាមួយ ខៀវ សំផន មានការទាក់ទងនឹងការបញ្ជាក់ការពិតចំពោះការចោទប្រកាន់ទាំងឡាយដែលបានលើកឡើងនៅក្នុងសវនាការលើកដំបូង។ នៅក្នុងការធ្វើសម្ភាសន៍នោះមានចម្លើយជាច្រើនពី ខៀវ សំផន ដែលទាក់ទងទៅនឹងប្រវត្តិដើមនៃរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ តួនាទីរបស់ និងការទទួលខុសត្រូវរបស់ជនជាប់ចោទ ក្នុងអំឡុងពេល និងក្រោយពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ រចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិតេយ្យ និងគោលនយោបាយរបស់រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះ រួមទាំងគោលនយោបាយទាក់ទងនឹងការជម្លៀសប្រជាជនស៊ីវិលចេញដោយបង្ខំ។

៣. ការធ្វើសម្ភាសន៍នេះ មិនមានផ្តល់ជូនមកឱ្យសហព្រះរាជអាជ្ញាទេ នៅមុនពេលបើកសវនាការជំនុំជម្រះក្តីកាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១។ ខ្សែវីដេអូនៃការធ្វើសម្ភាសន៍នេះត្រូវបានដាក់ផ្សាយនៅលើទំព័រវេបសាយ ដោយតតីយភាគីមួយដែលអះអាងថា គឺជា ខៀវ សំផន និងដែលត្រូវបានរកឃើញដោយការិយាល័យសហព្រះរាជអាជ្ញា កាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១។ ជាសរុបប្រវែងខ្សែវីដេអូនៃការធ្វើបទសម្ភាសន៍នេះមានរយៈពេលប្រាំបីម៉ោង និងម្ភៃបួននាទី(៨ម៉ោង២៤នាទី) ដែលហាក់ដូចជាត្រូវប្រើរយៈពេលពីរថ្ងៃដាច់ដោយឡែកពីគ្នា។ គេឃើញមានតែរូប ខៀវ សំផន ម្នាក់ឯងប៉ុណ្ណោះដែលបង្ហាញនៅលើអេក្រង់វីដេអូ ទោះបីជាមានឮសំឡេងអ្នកធ្វើសម្ភាសន៍ភេទប្រុសម្នាក់ដែលគ្មានអត្តសញ្ញាណ ដែលបានសួរសំនួរគាត់ នៅក្នុងពេលនោះ។

៤. សៀវភៅសរសេរដោយ Gina Chon និង ថេត សម្បត្តិ មានមូលដ្ឋានមួយផ្នែកធំនៅលើបទសម្ភាសន៍នានាជាមួយនឹង នួន ជា ។ សៀវភៅនេះ ក៏ទាក់ទងផងដែរទៅនឹងការពិតនៃការចោទ

ប្រកាន់នានាដែលបានលើកឡើងនៅក្នុងសវនាការដំបូង។ វាមានសេចក្តីថ្លែងនានា របស់ នួន ជា ទាក់ទងទៅនឹងសារតារប្រវត្តិសាស្ត្រនៃសម័យកម្ពុជាប្រជាធិបតេយ្យ, មុខងារ និង ការទទួលខុសត្រូវរបស់ជនជាប់ចោទនៅមុន ក្នុង និងក្រោយ សម័យកម្ពុជាប្រជាធិបតេយ្យ, រចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ និងគោនយោបាយនានារបស់រដ្ឋាភិបាលកម្ពុជាប្រជា ធិបតេយ្យ ដោយរួមទាំង គោលនយោបាយទាក់ទងទៅនឹងការជម្លៀសប្រជាពលរដ្ឋស៊ីវិលដោយបង្ខំផង។

៥. សហព្រះរាជអាជ្ញាទើបតែបានដឹងពីសៀវភៅនេះ ជាដំបូងនៅថ្ងៃពុធ ទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ នៅក្នុងបណ្ណាល័យរបស់ អវតក ។ បណ្ណាល័យបានទទួលសៀវភៅនេះនៅខែសីហា ឆ្នាំ២០១១ ។ សៀវភៅនេះបោះពុម្ពនៅឆ្នាំ២០១០ ។ ដូច្នេះហើយ នៅថ្ងៃសុក្រទី២ ខែធ្នូ ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់បង្ហាញសៀវភៅនេះជូនទៅអង្គជំនុំជម្រះសាលាដំបូង ព្រមទាំងភាគីទាំងអស់ តាមរយៈសារអេឡិចត្រូនិច។

៦. នៅក្នុងកាលៈទេសៈនេះ សហព្រះរាជអាជ្ញាពុំអាចដាក់បញ្ចូលខ្សែវីដេអូ ឬសៀវភៅនេះចូលទៅក្នុងបញ្ជីឯកសារចុងក្រោយរបស់ខ្លួនដែលបានដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១ បានឡើយ ដែលឯកសារទាំងនោះត្រូវបានតម្រូវឲ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុង ៣ សប្តាហ៍ដំបូងនៃសវនាការ[1]។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះដាក់ខ្សែវីដេអូបទសម្ភាសន៍ ព្រមទាំងសៀវភៅនេះ ចូលទៅក្នុងសំណុំរឿង ដោយអនុគ្រោះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |

[1] ឯកសារលេខ **E131/1/4** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញទាំងឡាយដែលត្រូវកោះហៅ ក្នុងអំឡុងពេលបីសប្តាហ៍ដំបូងនៃសវនាការ, ថ្ងៃទី១ វិច្ឆិកា ២០១១។